ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ១០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




កសវ

# Work Activities

ប្រចាំខែតុលា ឆ្នាំ២០១២



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកញ្ញា ឆ្នាំ២០១២ | ៣ |
| ៣- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

## សេចក្ដីព្រាងច្បាប់ស្ដីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១១

កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្ដម **អ៊ុំ កុសល** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្ដម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ត្រូវបានអនុវត្តក្នុងបរិការណ៍ដែលឥទ្ធិពលអវិជ្ជមាននៃការធ្លាក់ចុះសេដ្ឋកិច្ច និងវិបត្តិកលិយុគសកលលោក និងត្រូវជំនួសមកវិញដោយឥទ្ធិពលនៃវិបត្តិបំណុលនៅអឺរ៉ុប ហើយសភាពការណ៍ក្នុងប្រទេសក៏បានផ្លាស់ប្ដូរពីការធូរស្រាលខ្លះនៃទំនាស់ព្រំដែននៅតំបន់ប្រាសាទព្រះវិហារមកជាការប្រឈមនឹងគ្រោះទឹកជំនន់។ ទោះជាយ៉ាងណា រាជរដ្ឋាភិបាលមិនត្រូវតែជំនះបាននូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅនិងការប្រឈមទាំងនេះ ប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្ដិសិទ្ធប៉ុណ្ណោះទេ តែថែមទាំងសម្រេចបាននូវកំណើនសេដ្ឋកិច្ចមួយខ្ពស់ជាងការគ្រោងទុកនៅក្នុងច្បាប់ទៀតផង។



ការសម្រេចបាននូវលទ្ធផលដូចដែលបានគូសបញ្ជាក់ខាងលើគឺដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកប ដោយឆន្ទៈនយោបាយមោះមុត ឈ្លាសវៃ និងភ្លឺស្វាងរបស់រាជរដ្ឋាភិបាល និងបានដាក់ចេញនូវគោលនយោបាយនិងយុទ្ធសាស្ត្រត្រឹមត្រូវច្បាស់លាស់និងសមស្របព្រមទាំងមានរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយភាពស័ក្ដិសិទ្ធិនិងប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនឹងអាចចេញផុតពីវិបត្តិយ៉ាងឆាប់រហ័ស កម្ពុជាក៏សម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ អតិផរណាស្ថិតក្នុងសភាពគ្រប់គ្រងបាន និងអត្រាប្ដូរប្រាក់ក្នុងកម្រិតទាប ព្រមទាំងពន្លឿនបាននូវការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង ទាំងផ្នែកទន់ ដែលជាមូលដ្ឋានសម្រាប់ពង្រឹងនិងពង្រីកសកម្មភាពសេដ្ឋកិច្ច បង្កើន

កើនចំណូល និងលើកកម្ពស់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដែលធ្វើឲ្យរាជរដ្ឋាភិបាលសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំ ស្របតាមគោលដៅនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។

កំណើនសេដ្ឋកិច្ចកម្ពុជា ៧,១%នៅឆ្នាំ២០១១ ទល់នឹង៦% នៃការគ្រោងទុក គឺជាអត្រាមួយខ្ពស់តាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងជាអត្រាដែលមានភាពប្រហាក់ប្រហែលនឹងការសម្រេចបានរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីមួយចំនួនទៀតដែរ ដែលគេទទួលស្គាល់ថាជាក្បាលម៉ាស៊ីនកំណើនសម្រាប់សកលលោក។ កំណើននេះត្រូវបានរួមចំណែកមកពីវិស័យនាំមុខមួយចំនួនដូចជា វិស័យកាត់ដេរបានកើនឡើង ១៩,៩% វិស័យទេសចរណ៍បានកើនឡើង៦,៦% វិស័យសំណង់៧,៩% និងវិស័យកសិកម្ម៣,៦%។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវបានរក្សាឲ្យស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបានគឺប្រមាណ៥,៥%[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។





(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកញ្ញា ឆ្នាំ២០១២*

របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកញ្ញា ឆ្នាំ២០១២ នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងមានការអញ្ជើញចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។



## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកញ្ញា ឆ្នាំ២០១២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៣% ធៀបនឹងខែមុន និងកើនឡើង១,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន (ខែ១២រយៈពេល)។ ការឡើងថ្លៃទំនិញប្រើប្រាស់នាខែកញ្ញាធៀបនឹងខែមុន មានការរួមចំណែកនៃក្រុមម្ហូបអាហារ ៥៧% និង ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន ៤៣%។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | |
|---|---|---|
| *ក្រុមទំនិញ:* | *មុខទំនិញ:* | |
| ម្ហូបអាហារ : +០៨%, | អង្ករ : +៥,៩ % | បន្លែ: +៨,២% |
| សម្លៀកបំពាក់ និងស្បែកជើង : +៣៩%, | សាច់ជ្រូក : -១០៧%, | ឧស្ម័ន: +០,៨% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន : +២ ៨%, | សាច់គោស្រស់: +១៤ % | ប្រេងសាំង: +២៣%, |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ : +២,៥% | សាច់មាន់ : -៣៣%, | ប្រេងម៉ាស៊ូត: +៣៩%, ។ |
| ការដឹកជញ្ជូន: +១,០ % | ត្រីស្រស់ : -៤៣%, | |
| ភោជនីយដ្ឋាន: +៣៨%, | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំង៥ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១បម្រែបម្រួល.សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០–២០១២

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា[P] | វិច្ឆិកា[P] | ធ្នូ[P] | ប្រចាំឆ្នាំ[P] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥៨%, | ៥៤%, | ៥៤%, | ៤៨%, | ២២%, | ១៨%, | ១៣%, | ២,២% | ១,៤% | ១,៧% | ១,៧% | ១,៦% | ៣,១% |
| | ខែមុន | ១០, | ០៤, | ០៦%, | ០៥%, | -១១%, | ០១%, | ០ | ១,១% | ០,២% | ០,៣% | ០-,៧% | ០-,៩% | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦៥%, | ៧១%, | ៧១%, | ៦៤%, | ៦៧%, | ៥៣%, | ៥៦%, | ៤៩%, | ៥៥%, |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១៤%, | ០៥%, | ០៦%, | ០២%, | ១០%, | ០១%, | ៧%,០- | ៨%,០- | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |

P: តួលេខខែតុលា វិច្ឆិកា ធ្នូនិងប្រចាំឆ្នាំ២០១២ ជាតួលេខព្យាករដោយក តាមវិធីសាស្ត្រ ) .វ.ស.DECOMPOSITION )

ក្រាហ្វ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១១ និង២០១២ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




ក្រាហ្វបង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ ធៀប) នឹងខែដូចគ្នា២០១១ និង ២០១២ ឆ្នាំ ( និងអត្រាអតិផរណាព្យាករបីខែទៅមុខ ធៀប) នឹងខែដូចគ្នាឆ្នាំមុន( សម្រាប់ឆ្នាំ២០១២។

➡អត្រាប្តូរប្រាក់៖

| ប្រភេទ | អត្រាខែកញ្ញា ២០១២ | អត្រាខែសីហា ២០១២ | អត្រាខែកញ្ញា ២០១១ | ប្រភេទ | អត្រាខែកញ្ញា ២០១២ | អត្រាខែសីហា ២០១២ | អត្រាខែកញ្ញា ២០១១ |
|---|---|---|---|---|---|---|---|
| រដុល្លារ/ | ៤០៤៣រ/១$ | ៤០៤៥ រ/១$ | ៤០៨០រ/១$ | បាតដុល្លារ/ | ៣០,៨៦បាត/១$ | ៣១,៣៧បាត/១$ | ៣១,១៧បាត/១$ |
| របាត/ | ១៣១រ/១បាត | ១២៩រ/១បាត | ១៣១រ/១បាត | ដុងដុល្លារ/ | ២០៨៦០ដុង/១$ | ២០៨៤០ដុង/១$ | ២០៧៨៥ដុង/១$ |
| រដុង/ | ០,១៩៣រ/១ដុង | ០,១៩៤ | ០,១៩៥រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែកញ្ញា ឆ្នាំ២០១២ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

- *ចំណូលថវិកាជាតិអនុវត្តបានចំនួន ៦០៣៣, ពាន់លានរៀលមធ្យម) ប្រចាំខែ ៧២នៃ %គម្រោង( ក្នុងនោះ*ចំណូលចរន្តចំនួន ៥៨៦,៩ពាន់លានរៀលមធ្យម)ប្រចាំខែ ១០០(នៃគម្រោង % និងចំណូលមូលធនចំនួន ១៦,៤*ពាន់លានរៀល*។

- បើធៀបនឹងខែមុនចំណូលថវិកាជាតិថយចុះ១១% ប៉ុន្តែកើនឡើង ២៦% *ធៀបនឹងខែដូចគ្នាឆ្នាំមុន* ។ ការថយចុះធៀបនឹងខែមុន បណ្តាលមកពីចំណូលចរន្តថយចុះ១% និងចំណូលមូលធនថយចុះ៨១%។

- នៅក្នុងចំណូលចរន្ត៖

ក្រាហ្វ ២និង ២០១១ ចំណូលថវិកាជាតិ ឆ្នាំ . ២០១២
(ពាន់លានរៀល)



✓ ចំណូលសារពើពន្ធមានចំនួន ៤៨៦,៧ពាន់លានរៀល ថយចុះ៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ១០០,២ពាន់លានរៀល កើនឡើង២១% ធៀបនឹងខែមុន និងកើនឡើង ៩៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| ក្នុងចំណូលសារពើពន្ធ )ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន( | | ក្នុងចំណូលមិនមែនសារពើពន្ធ )ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន( | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : +១% | +១៥% | ➢ នេសាទ: -៥៩% | -៣៥% |
| ➢ ចំណូលពន្ធដារ : -៨% | +២% | ➢ រុក្ខាប្រមាញ់ : -៥០% | -៨១% |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +៧% | +១២% | ➢ អាកាសចរណ៍ស៊ីវិល : -៩១% | +១៦% |
| ✧ កាស៊ីណូ : +៨១% | +១% | ➢ ផលទុនទេសចរណ៍: -៩៩% | -៩៩% |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៥៦% | +១១% | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +៩២៧% | +៤៤% |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ: -១៤% | +២៣% | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): -២% | +៤% |

↳ ***ចំណាយថវិកាជាតិ*** អនុវត្តបានចំនួន ៤២៧ ពាន់លានរៀល )*មធ្យមប្រចាំខែ ៦០* (*នៃគម្រោង* %ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៣៤៤ ពាន់លានរៀល )*មធ្យមប្រចាំខែ ៩០*និង (*នៃគម្រោង* %**ចំណាយមូលធន**ចំនួន ៨៣ ពាន់លានរៀល។

↳ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** ថយចុះ ២៩% និងថយចុះ ៣២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តថយចុះ ៣៤% ធៀបនឹងខែមុន និងថយចុះ ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯ**ចំណាយមូលធន** កើនឡើង ៥% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៤៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

↳ *ថវិកាជាតិនៃខែកញ្ញាមាន**អតិរេក ១៧៦** ពាន់លានរៀល ស្មើនឹង ៤៤ លានដុល្លារ ស.រ.អា* ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកញ្ញា ឆ្នាំ២០១២ មានលក្ខណៈដូចខាងក្រោម៖

↳ រូបិយវត្ថុ $M_2$ មានចំនួន ២៦ ៨៦៤ ពាន់លានរៀល ថយចុះ 0,៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

↳ការថយចុះនៃរូបិយវត្ថុ $M_2$ ធៀបនឹងខែមុន បណ្តាលមកពីរូបិយវត្ថុក្រៅធនាគារថយចុះ ២% ប្រាក់បញ្ញើចរន្តថយចុះ ១៥% និងប្រាក់បញ្ញើជារូបិយបណ្ណ ថយចុះ 0,៣% ។

↳យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៧នៃរូបិយវត្ថុ % $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣។%

ក្រាហ្វ៣: សមាសធាតុរូបិយវត្ថុ ខែកញ្ញា ឆ្នាំ២០១២



**សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$**

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុង និងក្រៅធនាគារ | ១៩,២% | ១៨,៣% | ១៩,៦% | ១៩,៣% | ១៨,៦% | ១៨% | ១៧% | ១៧% | ១៧% | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,២% | ១៥,២% | ១៥,៣% | ១៤,៨% | ១៤,៧% | ១៤% | ១៤% | ១៤% | ១៣% | | | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែកញ្ញា២០១២: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន**




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣២៨៥ លានដុល្លារ កើនឡើង ២,៨% ធៀបនឹងខែមុន និងកើនឡើង ១៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ៩០៩១ ពាន់លានរៀល ថយចុះ ២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** មានចំនួន **២១៤១២ ពាន់លានរៀល** កើនឡើង ២,៧% ធៀបនឹងខែមុន និងកើនឡើង ៣០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** (ខែកញ្ញាមិនទាន់មានតួលេខ)
- ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគារពាណិជ្ជនាខែកញ្ញា៖

| *ប្រភេទអត្រាការប្រាក់* | *កញ្ញា ២០១២* | *សីហា ២០១២* | *កញ្ញា ២០១១* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៩៤% | ៦,៥២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៨២% | ១៩,០៨% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,៤៤% | ៤,៤២% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៩៧% | ១៤,៨៧% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកញ្ញាឆ្នាំ២០១២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ ផលិតកម្មនេសាទមានចំនួន ៨០ពាន់តោន កើនឡើង៣% ធៀបនឹងខែមុន និងកើនឡើង៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- **ឧស្សាហកម្ម៖**
  - ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២៩៤,៧ GWh កើនឡើង១% ធៀបនឹងខែមុន និងកើនឡើង៣៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ១៣៧,៣ GWh កើនឡើង៤៣% ធៀបនឹងខែមុន និងកើនឡើង ១៤៤០% ធៀបនឹងខែដូចគ្នាឆ្នាំមុន (វារីអគ្គិសនីកំចាយចាប់ដំណើរការក្នុងឆ្នាំ២០១២)។

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤១០ លានដុល្លារ ថយចុះ ៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| *ប្រភេទ* | *ចំនួន— កញ្ញា ២០១២* | *ចំនួន—សីហា ២០១២* | *ចំនួន—កញ្ញា ២០១១* |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៣០ | ១១ | ១៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ០ | ១៥ | ១៥ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ០ | ២៤ | ១៥ |

**សម្គាល់** : តួលេខខាងលើនេះ ជាការចុះបញ្ជីនៅក្រសួងឧស្សាហកម្មប៉ុណ្ណោះ។ សម្រាប់រោងចក្រ និងឧស្សាហកម្មធុនតូច និងមធ្យមមួយចំនួនដែលបានធ្វើប្រតិភូកម្មឲ្យទៅមន្ទីរឧស្សាហកម្មខេត្ត-ក្រុង (ប្រកាស ៦០៧) មិនមានក្នុងតួលេខនេះទេ។ ECOSOCC នឹងធ្វើបច្ចុប្បន្នភាពតួលេខដែលគ្របដណ្តប់ទូទាំងប្រទេស នៅពេលក្រោយបន្ទាប់ពីទទួលបានការបំពេញតួលេខពីក្រសួងឧស្សាហកម្មតាមសំណូមពររបស់ ECOSOCC ។

**សំណង់** (ការអនុញ្ញាត)៖

✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៨១០ ពាន់ម$^2$ កើនឡើង ៨៦% ធៀបនឹងខែមុន និងកើនឡើង ៩៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹងចំនួន ៣០២ លានដុល្លារ កើនឡើង ១០៦% ធៀបនឹងខែមុន និងកើនឡើង ១៥៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បង ៗមាន៖

| *ប្រភេទ* | *ពាន់ម$^2$ —កញ្ញា ២០១២* | *ពាន់ម$^2$ —សីហា២០១២* | *ពាន់ម$^2$ —កញ្ញា ២០១១* |
|---|---|---|---|
| ▪ លំនៅឋាន | ១៧០ | ២០១ | ១២៨ |
| ▪ ឧស្សាហកម្ម | ១២៣ | ១០៥ | ២១៧ |
| ▪ ពាណិជ្ជកម្ម | ៤៩២ | ៨៦ | ១៩ |
| ... | | | |
| អនុញ្ញាតសរុប | ៨១០ | ៤៣៥ | ៤១៤ |

✓ **សំណង់ដែលពេញនិយមនាខែនេះគឺ** សំណង់ពាណិជ្ជកម្ម នៃផ្ទៃក្រឡា ៦១%)អនុញ្ញាតសរុប( សំណង់លំនៅឋាន ២១%) នៃផ្ទៃក្រឡាអនុញ្ញាតសរុបនិងសំណង់ (ឧស្សាហកម្មនៃផ្ទៃក្រឡា ១៥%) អនុញ្ញាតសរុប( ។

**ការងារ៖**

| *ប្រភេទ* | *ចំនួន (នាក់)—កញ្ញា ២០១២* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ៣៩៦២ | ៧១%+ | ៥២%+ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៧០២៤ | ៥៤%+ | ១៤៣%+ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៣០៦០ | ២២%+ | ២០៤%+ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣៧៩៧ | ៨៦+% | ១០១+% |

**វិនិយោគ៖**

✓ គម្រោងវិនិយោគអនុញ្ញាតដោយ គក្នុងខែកញ្ញាមានចំនួន (ថ្មីនិងពង្រីក) .ក.អ.ក/.ក.វ. ១០ គម្រោង ដែលជាទុនវិនិយោគស្មើនឹង ៦៤ លានដុល្លារ។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន ១១ ពាន់នាក់។

| ប្រភេទ | កញ្ញា២០១២ | សីហា២០១២ | កញ្ញា២០១១ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៦៤ | ១៩១ | ៦៩១ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៥ | ៩៨ | ២៧ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៥៩ (១៣) | ៨៧ (១) | ៦០៦ (៥៥០) |
| វិស័យទេសចរណ៍ | ០ | ០ | ៥៨ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ៥ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១០ | ២៣ | ២០ |
| បង្កើតការងារ (ពាន់នាក់) | ១១ | ៣៤ | ១៧ |

**សេវាកម្ម និងទេសចរណ៍៖**

✓ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន – កញ្ញា២០១២ | ចំនួន – សីហា២០១២ | ចំនួន – កញ្ញា២០១១ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣០៦ | ៣១១ | ២១៧ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៣ | ៧ | ៤ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១៦៣ | ២១៣ | ២៥២ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៣៩៨ពាន់តោន ថយចុះ២០% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | |
|---|---|
| ▪ កំពង់ផែភ្នំពេញ: –១៣% (+៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: –៥០% (–៣៥%) |
| ▪ កំពង់ផែកំពង់សោម: –១៤% (+៥%) | ▪ កំពង់ផែឧកញ៉ាម៉ុង: –២៩% (+៣៥៧%) |

**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍:**

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤ | –៤៤% | –៣០% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៦ | +២៤% | +៨៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៥៤ | –២១% | +៤% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៦ | +២% | –១៤% |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៤៣ | –១៧% | +១៦% |
| ✓ តាមផ្លូវអាកាស | ១០៨ | –២០% | +១៤% |
| ✓ តាមផ្លូវគោក និងទឹក | ១៥៨ | –១៥% | +១៧% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលនាខែកញ្ញាមានចំនួន ៣០១៩ ពាន់លានរៀល (ស្មើនឹង ៧៤៧ លានដុល្លារ ស.រ.អា.) កើនឡើង ១៦% ធៀបនឹងខែមុន និងកើនឡើង ៥២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១២% | +៥% | ប្រេងម៉ាស៊ូត | –៩% | +១១% |
| ដែកសំណង់ | +៤៦% | –២១% | ឧស្ម័ន | –១% | +២៦% |
| គ្រឿងអេឡិចត្រូនិក | +៣០% | –១% | ស៊ីម៉ង់ត៍ | –៨% | +៦៨% |

| | | | | | |
|---|---|---|---|---|---|
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +១៣% | +៤៦% | រថយន្តសរុប (រ.ល.ព) | -៩% | +១៣% |
| ម៉ូតូ (គ្រឿង) | ០ | +៣៥% | រថយន្តសរុប (គ្រឿង) | -៧% | +៩% |
| ជី និងថ្នាំកសិកម្ម | +៤២% | +៤៥% | អង្ករ | -៨១% | +៣៤២៥% |
| ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៧% | +៣៧% | ផ្លែឈើ និងបន្លែ | -៧៩% | +៣% |

➡ **ការនាំចេញ** ក្នុងខែកញ្ញាឆ្នាំ២០១២ មានចំនួន ២០៦ ៣ពាន់លានរៀល ស្មើនឹង ៥១០ លានដុល្លារ ស ៦៨%) .អា.រ. នៃការនាំចូល( ថយចុះ ១១ %ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៨ % ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +២៥៥៥% | -៥៥% | វាយនភណ្ឌនិងស្បែកជើង | -១៦% | -២% |
| ផលិតផលនេសាទ | +៣៨៣% | -៥០% | អង្ករ | -៣២% | +៥% |
| កៅស៊ូ | +៧០% | +៧៨% | | | |

➡ ក្នុងខែកញ្ញានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៩៥៦ ពាន់លានរៀល ស្មើនឹង ២៣៦ លានដុល្លារ ស.អា.រ.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកញ្ញា ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថវិកាខេត្តរាជធានី- | +៨% | -៣៣% | ស្ថិតនៅក្នុងចំណូលពន្ធដារ |
| ២ | ទុនវិនិយោគអនុញ្ញាតដោយ ក.ក.អ. | -៦៦% | -៩១% | — |
| ៣ | ការនាំចូលអង្ករ (៧,៩ ពាន់តោន) | -៨១% | +៣៤២៥% | តួលេខនាំចូលអង្ករមានទំហំធំបីខែជាប់គ្នា |
| ៤ | នាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើង | -១៦% | -២% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

**១) ការត្រៀមខ្លួនរបស់កម្ពុជាដើម្បីចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន** (Asean Economic Community—AEC)

ក្នុងដំណើរការសេរីភាវូបនីយកម្មនៃសហគមន៍នេះនឹងមានលំហូរដោយសេរីនៃទំនិញ សេវា វិនិយោគ មូលធន និងពលកម្ម។ អត្រាពន្ធគយនិងរបាំងមិនមែនពន្ធគយនឹងត្រូវកាត់បន្ថយយ៉ាងខ្លាំង រួមជាមួយនឹងការបន្ធូរបន្ថយនីតិវិធីរដ្ឋបាល និងការិយាធិបតេយ្យ។ បណ្តាប្រទេសអាស៊ានក៏កំពុងរៀបចំខ្លួនដើម្បីប្រឈមនឹងបញ្ហាផង និងមានកាលានុវត្តភាពផងនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

ការចូលជាសមាជិក**សហគមន៍សេដ្ឋកិច្ចអាស៊ាន** អាចផ្តល់កាលានុវត្តភាពមួយចំនួនដល់កម្ពុជា ប៉ុន្តែយើងសូមលើកឡើងតែបញ្ហាប្រឈមមួយចំនួនដែលកម្ពុជាគួរយកចិត្តទុកដាក់ដូចខាងក្រោម :

ក. ការថយចុះនៃចំណូលពន្ធគយ ដែលបច្ចុប្បន្នកម្ពុជាពឹងផ្អែកលើចំណូលនេះប្រហែល ៥០%។ បញ្ហានេះតម្រូវឲ្យមានការលើកកម្ពស់ចំណូលពន្ធដារ និងកំណែទម្រង់ប្រព័ន្ធពន្ធដារ។

ខ. លំហូរសេរីនៃទំនិញ-សេវានឹងជះឥទ្ធិពលដល់សហគ្រាសធុនតូច និងមធ្យម ដែលនៅក្មេងខ្ចីនិងងាយរងគ្រោះរបស់កម្ពុជា។ គុណភាពទំនិញ និងសេវារបស់ក្រុមហ៊ុនកម្ពុជានៅមានកម្រិត ពិបាកប្រកួតប្រជែងជាមួយគូប្រកួតរបស់ខ្លួន។

គ. ពលករកម្ពុជាអាចពិបាកប្រកួតជាមួយពលករបរទេសក្នុងការទទួលការងារមួយចំនួនដែលមានជំនាញខ្ពស់ ទោះនៅក្នុងប្រទេសរបស់ខ្លួនក្តី ក្រៅប្រទេសក្តី ។

**២) ការខ្វះខាតនៃការផ្គត់ផ្គង់ទំនិញកសិកម្ម ដូចជាសាច់គោ-ជ្រូក និងបន្លែ**

អត្រាអតិផរណាកម្ពុជាជាទូទៅ បណ្តាលមកពីការឡើងថ្លៃក្រុមម្ហូបអាហារ ដែលក្នុងនោះក្រុមសាច់ និងបន្លែដើរតួយ៉ាងសំខាន់។ ការចិញ្ចឹមសត្វនៅកម្ពុជានៅមានកម្រិត ដោយសារលក្ខណៈចិញ្ចឹមជាគ្រួសារខ្នាតតូច ខ្វះយុទ្ធសាស្ត្រ និងបច្ចេកទេស។ ក៏ដូចគ្នានេះដែរចំពោះការផ្គត់ផ្គង់បន្លែ ដែលមានកម្រិតប្រហែលតែ ៥០% នៃតម្រូវការក្នុងស្រុកប៉ុណ្ណោះ។

**៣) បញ្ហាកកស្ទះចរាចរណ៍នៅទីក្រុងភ្នំពេញ**

ចរាចរណ៍នៅទីក្រុងភ្នំពេញកាន់តែមានការកកស្ទះខ្លាំងឡើងៗ ដែលបង្កការខាតបង់យ៉ាងច្រើន ទាំងពេលវេលា ប្រាក់កាស សុខភាព និងការលំបាកដល់សកម្មភាពសេដ្ឋកិច្ច។ នេះជាបញ្ហាអាទិភាព ដែលតម្រូវឲ្យមានដំណោះស្រាយជាយុទ្ធសាស្ត្រថ្នាក់ជាតិរយៈពេលវែង។

**៤) ការផលិត និងការចែកចាយស្រា-ស**

ស្រា-សជាផលិតផលប្រពៃណីរបស់ប្រជាជនខ្មែរ ដែលចេះផលិតតៗគ្នា ចែកចាយ និងប្រើប្រាស់ក្នុងប្រទេស ទាំងនៅជនបទ ទាំងនៅទីក្រុង ។ កន្លងមកមានករណីពុលស្រា-ស និងស្លាប់នៅក្នុងប្រទេសកម្ពុជា ដោយសារការប្រើធាតុផ្សំមិនត្រឹមត្រូវ ឬមេស្រាមានជាតិពុលដែលមិនមែនជាការផលិតតាមក្បួនខ្នាតត្រឹមត្រូវ។

***ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖***

១) ប្រព័ន្ធពន្ធដារកម្ពុជាជៀសមិនរួចពីកំណែទម្រង់ស៊ីជំរៅទេ នៅពេលដែលមានការធ្លាក់ចុះនៃចំណូលពន្ធ-គយ ។ កំណែទម្រង់ពិតជាមានការពាក់ព័ន្ធនឹង៖

ក. ការបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ

ខ. លទ្ធភាពនៃការបញ្ចូលប្រភេទពន្ធថ្មី ដែលមានប្រសិទ្ធភាព និងមិនប៉ះពាល់ខ្លាំងដល់សមធម៌សង្គម

គ. ការពិនិត្យរបបពន្ធដារឡើងវិញ ដោយមានការថ្លឹងថ្លែងរវាងរបបពិត និងរបបម៉ៅការ

ឃ. **ការសម្រួលនីតិវិធីបង់ពន្ធ ដើម្បីឲ្យ**ការបង់ពន្ធគ្រប់ប្រភេទ**អាចធ្វើបាន**តាមរយៈប្រព័ន្ធធនាគារ

២) សហគ្រាសធុនតូច និងមធ្យមកម្ពុជាក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ត្រូវតែមានភាពប្រកួតប្រជែងខ្ពស់។ ដូច្នេះយើងត្រូវបង្កើតបរិយាកាសអំណោយផលសម្រាប់ការរីកលូតលាស់របស់សហគ្រាសទាំងនេះ។

ក. ការ**កាត់**បន្ថយនីតិវិធីការិយាធិបតេយ្យ

+ កាត់បន្ថយភាពជាន់ភារកិច្ចគ្នានៃសមត្ថកិច្ចរបស់អាជ្ញាធរដែលគ្រប់គ្រងធុរកិច្ចធុនតូច និងមធ្យម

+ ធ្វើឲ្យកាន់តែសាមញ្ញ និងមានតម្លាភាពនូវបែបបទ និងនីតិវិធីនៃការបង្កើត ដំណើរការ និងការបិទធុរកិច្ច

+ រយៈពេលដែលត្រូវចំណាយលើនីតិវិធីគួរតែអប្បបរមាដែលអាចទៅរួច

ខ. ការ**កាត់**បន្ថយនូវចំណាយ**មិនចាំបាច់**របស់ធុរកិច្ចធុនតូច និងមធ្យម

៣) គួរពង្រឹងការគ្រប់គ្រងការផលិត និងការចែកចាយស្រា-ស។ ស្រា-សជាប្រភេទទំនិញដែលមានការប្រើប្រាស់យ៉ាងទូលំទូលាយ ដូច្នេះយើងអាចទាញផលចំណេញពីការផលិត និងការប្រើប្រាស់ទំនិញនេះបាន បើមិនសម្រាប់ពេលបច្ចុប្បន្ន ក៏សម្រាប់ថ្ងៃអនាគតដែរ។ ម្យ៉ាងវិញទៀត ឈ្មោះ របៀបផលិត និងគុណភាពស្រា-ស គួរត្រូវបានអភិរក្ស និងលើកកម្ពស់ ក្នុងនាមជាទំនិញប្រពៃណីជាតិ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១០/១២<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គីភ័យ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌ មន្ត្រីជាន់ខ្ពស់ សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះអង្គឌួងជាគ្រឹះស្ថានសាធារណៈរដ្ឋបាល<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/១០/១២<br>ម៉ោង ១០ : ៣០ នាទី | ចូលរួមជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យគណៈប្រតិភូរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយលោក Olaf Unteroberdoerster ប្រធានបេសកកម្មអង្គការ IMF ទទួលបន្ទុកនៅព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានផ្នែកសិក្សាតំបន់របស់អង្គការ IMF ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ចូលជួប សម្តែងការគួរសម និងពិភាក្សាការងារ៖<br>១-បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា និងចក្ខុវិស័យរយៈពេលខ្លី។<br>២-សម្បទានរ៉ែ និងប្រេង និងចក្ខុវិស័យផ្នែកផលិតកម្ម។<br>៣-កំណែទម្រង់សេវាសាធារណៈ និងច្បាប់ប្រឆាំងអំពើពុករលួយ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៣/១០/១២<br>ម៉ោង ០៨ : ៣០ នាទី | ជាអធិបតីភាព ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ៤ | ០៣/១០/១២<br>ម៉ោង ១៦ : ៤០ នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីបិទសិក្ខាសាលាផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ៥ | ០៤/១០/១២<br>ម៉ោង ០៩ : ០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាដោះស្រាយបញ្ហា លំនៅឋានប្រជាពលរដ្ឋនៅជាប់របង នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៤/១០/១២<br>ម៉ោង ១៩ : ៣០នាទី | ចូលរួមក្នុងពិធីពិសាភោជនាហារពេលល្ងាច ជាមួយអគ្គរដ្ឋទូតបារាំង នៅស្ថានទូតបារាំង។ |
| ៧ | ០៥/១០/១២<br>ម៉ោង ១២ : ៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីជប់លៀងនៅស្ថានទូតបារាំង នៅស្ថានទូតបារាំង។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ០៥/១០/១២<br>ម៉ោង ១៥ : ៣០នាទី | ដឹកនាំកិច្ចប្រជុំ បើកឯកសារដេញថ្លៃលើការងារជួសជុលផ្លូវវង់តូច ប្រវែង ៣គីឡូម៉ែត្រ ក្នុងខេត្តសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ០៨/១០/១២<br>ម៉ោង ១៥ : ៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។<br>២-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-សេចក្តីព្រាងសារាចរ និងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តី ព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ០៩/១០/១២<br>ម៉ោង ០៨ : ០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ពង្រីកកំណាត់ផ្លូវជាតិលេខ៥ ប្រវែង ៣០,១៤៥ គម ពីស្ពានជ្រោយចង្វារ ដល់ស្ពានព្រែកក្តាម ក្រោមកម្ចីឥណទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិគ្រួស សង្កាត់សំរោង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ |
| ១១ | ១០/១០/១២<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារថ្មី និងប្រព័ន្ធទិន្នន័យរបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសហប្រធានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅអគារសាលាឧទ្ធរណ៍ថ្មី ទល់មុខព្រះបរមរាជវាំង។ |
| ១២ | ១០/១០/១២<br>ម៉ោង ១៨ : ០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលនិងពិសាភោជនាហារសាមគ្គី តាមការអញ្ជើញរបស់ប្រធានគណៈមេធាវីអាណត្តិទី៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| ១៣ | ១១/១០/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់ និស្សិតសាកលវិទ្យាល័យន័រតុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៤ | ១១/១០/១២<br>ម៉ោង ១៨ : ៣០នាទី | ចូលរួមក្នុងពិធីជប់លៀងជាមួយអគ្គរដ្ឋទូតបារាំង នៅស្ថានទូតបារាំង។ |
| ១៥ | ១៧/១០/១២<br>ម៉ោង ១៥ : ០០នាទី | ចូលរួមក្នុងព្រះរាជពិធីទទួលព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៦ | ១៨/១០/១២<br>ម៉ោង ១៤ : ៣០នាទី | ចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលាកញ្ញា ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៧ | ១៩/១០/១២<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅព្រះបរមរាជវាំង។ |
| ១៨ | ២២/១០/១២<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចែកប័ណ្ណកម្មសិទ្ធិដីធ្លី ជូនប្រជាពលរដ្ឋក្នុងឃុំតាអូ ស្រុកគិរីវង់ ខេត្តតាកែវ ក្រោមអធិបតីភាពឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅឃុំតាអូ ស្រុកគិរីវង់ ខេត្តតាកែវ។ |
| ១៩ | ២៣/១០/១២<br>ម៉ោង ១៥ : ៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១។<br>៣-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ២៤/១០/១២<br>ម៉ោង ០៩ : ៣០នាទី | ដឹកនាំក្រុមការងារគណៈកម្មការព្រលានយន្តហោះ និងអាជ្ញាធរដែនដី ចុះត្រួតពិនិត្យរបងបាក់ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២១ | ២៥/១០/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន លើកទី ៨ (The Eight ASEAN Socio-Cultural Community Council Meeting) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២២ | ២៥/១០/១២<br>ម៉ោង ១៥ : ៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២៣ | ២៦/១០/១២<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១១។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២៤ | ២៩/១០/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២៥ | ៣០/១០/១២ ម៉ោង ០៨ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និសីទ ស្តីពីការសម្រេចឲ្យបានសហគមន៍អាស៊ាន ដែលមានសមាហ- រណកម្ម ការប្រកួតប្រជែងមានសមធម៌ និងភាពរឹងមាំ (Realizing a more Integrated, Competitive, Equitable and Resilient ASEAN Community) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១០/១២ ម៉ោង ១៧:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធជើងហោះហើររបស់ក្រុមហ៊ុន Tiger Airway ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ២ | ១០/១០/១២ ម៉ោង ០៨:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារថ្មី និងប្រព័ន្ធទិន្នន័យរបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសហប្រធានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅអគារសាលាឧទ្ធរណ៍ថ្មី ទល់មុខព្រះបរមរាជវាំង។ |
| ៣ | ២៣/១០/១២ ម៉ោង ០៨:៣០ នាទី | ជាអធិបតីភាពនៅក្នុងសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ៤ | ២៥/១០/១២ ម៉ោង ០៨:៣០ នាទី | ជាអធិបតីភាពនៅក្នុងសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ |
| ៥ | ២៥/១០/១២ ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសិក្ខាសាលា ស្តីពីការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ៦ | ២៦/១០/១២ ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធមជ្ឈមណ្ឌលកីឡាតៃខ្វាន់ដូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅពហុកីឡដ្ឋានជាតិអូឡាំពិក។ |

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១០/១២ ម៉ោង ១៧:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធជើងហោះហើររបស់ក្រុមហ៊ុន Tiger Airway ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ២ | ១០/១០/១២ ម៉ោង ០៨:៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារថ្មី និងប្រព័ន្ធទិន្នន័យរបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាសហប្រធានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅអគារសាលាឧទ្ធរណ៍ថ្មី ទល់មុខព្រះបរមរាជវាំង។ |
| ៣ | ២៥/១០/១២ ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបិទសិក្ខាសាលា ស្តីពីការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ៤ | ២៦/១០/១២ ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធមជ្ឈមណ្ឌលកីឡាតៃខ្វាន់ដូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅពហុកីឡដ្ឋានជាតិអូឡាំពិក។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១០/១២ ម៉ោង ១៧:៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធជើងហោះហើរ របស់ក្រុមហ៊ុន Tiger Airway ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ២ | ០៩/១០/១២ ម៉ោង ០៩:០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយ។<br>២-សេចក្ដីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-សេចក្ដីព្រាងសារាចរ និងគោលការណែនាំស្ដីពីនីតិវិធី និងវិធាន នៃការតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។<br>៤-បញ្ហាផ្សេងៗ។<br>នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១០/១០/១២ ម៉ោង ០៨:៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារថ្មី និងប្រព័ន្ធទិន្នន័យរបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាសហប្រធានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅអគារសាលាឧទ្ធរណ៍ថ្មី ទល់មុខព្រះបរមរាជវាំង។ |
| ៤ | ២៥/១០/១២ ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសិក្ខាសាលា ស្ដីពីការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ៥ | ២៦/១០/១២ ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធមជ្ឈមណ្ឌលកីឡាតៃខ្វាន់ដូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅពហុកីឡាដ្ឋានជាតិអូឡាំពិក។ |

# សិក្ខាសាលាស្តីពី ការផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត

ក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)តាមរយៈក្រុមហ៊ុន POHL Consulting & Associates បានរួមគ្នារៀបចំសិក្ខាសាលាចំនួនពីរលើក ស្តីពីការផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។ លើកទី១-នៅរាជបណ្ឌិតសភាកម្ពុជា នាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ និងលើកទី២-នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២។

ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជានាយកគម្រោង RIA ជាអធិបតីនៅក្នុងសិក្ខាសាលាទាំងពីរនេះ ក្នុងនាមឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។



ក្នុងឱកាសទាំងពីរនោះ ឯកឧត្តម **ឃឹម ណុលសន** បានមានប្រសាសន៍ថា “ ក្នុងនាមឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង សូមស្វាគមន៍ ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ និស្សិត លោក លោកស្រី ដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាបង្ហាញពីគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ដែលហៅកាត់ថាគម្រោង RIA ) នាព្រឹកនេះ។




គ្រប់ប្រទេសទាំងអស់ ត្រូវការច្បាប់ បទប្បញ្ញត្តិដើម្បីគ្រប់គ្រងប្រទេស សេដ្ឋកិច្ច និងឥរិយាបថរបស់មនុស្ស។ យ៉ាងណាក៏ដោយ ច្បាប់និងបទប្បញ្ញត្តិទាំងនោះ ត្រូវតែមានការតាក់តែងឡើងដោយមានការប្រុងប្រយ័ត្ន ដើម្បីជៀសវាងកុំឲ្យមានផលប៉ះពាល់ដែលមិនបានរំពឹងទុក ឬផលខុសឆ្គងផ្សេងៗ ដូចជាការរឹតបន្តឹងការប្រកួតប្រជែង ឬការដាក់បន្ទុកចំណាយកាតូកិច្ចដ៏ធ្ងន់ធ្ងរដែលមិនចាំបាច់ ទៅលើអ្នកទាំងឡាយណាដែលរងផលប៉ះពាល់ដោយសារច្បាប់និងបទប្បញ្ញត្តិទាំងនោះ។ រដ្ឋាភិបាលត្រូវវាយតម្លៃដោយប្រយ័ត្នប្រយែងពីតម្លៃ និងផលប្រយោជន៍នៃការដាក់បញ្ចូលបញ្ញត្តិកម្មថ្មី ដើម្បីជៀសវាងការប៉ះពាល់អវិជ្ជមានមិនចាំបាច់លើធុរកិច្ច និងសង្គម ហើយត្រូវធានាថាបញ្ញត្តិកម្មទាំងនោះ ប្រតិបត្តិបានយ៉ាងប្រសិទ្ធិភាពពីអ្នកពាក់ព័ន្ធ។

ប្រទេសកម្ពុជាអនុវត្តសេដ្ឋកិច្ចទីផ្សារ និងជាសមាជិកអង្គការពាណិជ្ជកម្មអន្តរជាតិ(WTO) ដែលទាមទារឲ្យប្រទេសកម្ពុជាត្រូវតែមានសមត្ថភាពប្រកួតប្រជែងនៅក្នុងទីផ្សារអន្តរជាតិ។ នៅក្នុងសកលភាវូបនីយកម្មទីផ្សារ មូលធនអាចចល័តដោយសេរី ហើយលំហូរវិនិយោគនឹងចូលទៅប្រទេសដែលមានផលិតភាពខ្ពស់ជាងគេ។ ហេតុដូច្នេះធុរកិច្ចមិនអាចទទួលយកបន្ទុកចំណាយកាតព្វកិច្ចខ្ពស់នោះទេ ដែលធ្វើឲ្យពួកគេខ្វះផលិតភាព និងមិនមានលទ្ធភាពប្រកួតប្រជែងបាន។

ជាការពិតណាស់ការកាត់បន្ថយបន្ទុកចំណាយកាតូកិច្ចបញ្ញត្តិកម្ម គឺជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រដែលមានប្រសិទ្ធិភាពដើម្បីធ្វើឲ្យសេដ្ឋកិច្ចមានលក្ខណៈប្រកួតប្រជែង។ RIA នឹងធ្វើឲ្យលិខិតបទដ្ឋានគតិយុត្តរបស់យើងមានប្រសិទ្ធិភាពនិងប្រសិទ្ធិផល និងរួមចំណែកដល់ការធ្វើឲ្យធុរកិច្ចមានសមត្ថភាពប្រកួតប្រជែង ដែលនឹងជំរុញកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់ និងកម្រិតជីវភាពរស់នៅកាន់តែប្រសើរឡើង។ ការកាត់បន្ថយចំណាយកាតព្វកិច្ចបញ្ញត្តិកម្ម គឺជាអត្ថប្រយោជន៍តែមួយគត់របស់ RIA ហើយ RIA នេះ ធ្វើឲ្យការសម្រេចចិត្តមានតម្លាភាពផង និងជួយដល់អភិបាលកិច្ចល្អផង។ លទ្ធផលដ៏មានអត្ថប្រយោជន៍ទាំងនេះ ដែលបានមកពី



RIA នឹងស្របតាមគោលដៅយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី២នៃរាជរដ្ឋាភិបាលកម្ពុជា គឺកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធិភាព ក្រោមការដឹកនាំដ៏ឆ្លៀសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

RIA ត្រូវបានគេអនុវត្តនៅក្នុងប្រទេសជាច្រើន គឺជាភស្តុតាងមួយដែលបង្ហាញថា RIA មានប្រយោជន៍ ហើយត្រូវបានគេអនុវត្តនៅតាមទម្រង់ផ្សេងៗគ្នា។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អូស្ត្រាលី និងញូស៊ីឡេន បានអនុវត្ត RIA ពេញលេញ។ ម៉្យាងវិញទៀតស្ទើរតែទាំងអស់នៃប្រទេសជាសមាជិក OECD (អង្គការសម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច) បានអនុវត្ត RIA ក្នុងទម្រង់ផ្សេងៗគ្នា។ ហើយប្រទេសដទៃទៀត ដូចជាប្រទេសឡាវ ហ្វីលីពីន ឥណ្ឌូនេស៊ី និងថៃ កំពុងតែធ្វើការសាកល្បងRIA ដូចកម្ពុជាដែរ។ សំខាន់ជាងនេះទៅទៀត អាស៊ានបានចេញគោលការណ៍ណែនាំស្តីពី RIA ហើយប្រទេសកម្ពុជាក៏បានយកគំរូដូចគ្នានេះដែរ។ ទៅអនាគតអាស៊ាន នឹងតម្រូវឲ្យការរៀបចំគ្រប់លិខិតបទដ្ឋានគតិយុត្តបច្ចេកទេស អនុវត្តតាមនិតិវិធី RIA។ គម្រោង RIA នៅប្រទេសកម្ពុជា នឹងគោរពតាមលក្ខខណ្ឌរបស់អាស៊ានផងដែរ។ ម៉្យាងវិញទៀត រនាំងពាណិជ្ជកម្មរបស់សហគមន៍អាស៊ាននឹងត្រូវកាត់បន្ថយជាអតិបរិមាក្នុងឆ្នាំ២០១៥ ហើយពេលនោះទំនិញនិងសេវាកម្មអាចហូរឆ្លងប្រទេសនីមួយៗដោយសេរី។ ការអនុវត្ត RIA នឹងជួយឲ្យប្រទេសកម្ពុជាសម្របខ្លួនក្នុងការវិវឌ្ឍនេះ។ តាមការសិក្សាឃើញថា ការចំណាយកាតព្វកិច្ចបញ្ញត្តិកម្ម គឺជាបន្ទុកដ៏ធ្ងន់ធ្ងរមួយចំពោះធុរកិច្ច។ គណៈកម្មការផលិតភាពនៃប្រទេសអូស្ត្រាលី បានបង្ហាញថាបន្ទុកចំណាយកាតព្វកិច្ចបញ្ញត្តិកម្មមានតម្លៃស្មើនឹង៤% នៃផលិតផលសរុបក្នុងស្រុក(GDP)។ គណៈកម្មការនេះក៏បានរកឃើញផងដែរថា ការចំណាយកាតព្វកិច្ចរដ្ឋបាលអាចត្រូវកាត់បន្ថយបានប្រហែល ២៥%។ តាមការសិក្សាអំពីការចំណាយកាតព្វកិច្ច

រដ្ឋបាល ដោយធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងប្រទេសឡាវ បានបង្ហាញថាបន្ទុកចំណាយកាតព្វកិច្ចបញ្ញត្តិកម្ម មានតម្លៃ ២% នៃផលិតផលសរុបក្នុងស្រុក (GDP)។ នៅក្នុងទីផ្សារប្រកួតប្រជែង គ្មានប្រទេសណាមួយអាច មានលទ្ធភាពទទួលយកបាននូវការដាក់បន្ទុកចំណាយកាតព្វកិច្ចដ៏ធ្ងន់ធ្ងរបែបនេះនោះទេ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ដោយការអនុវត្ត RIA ប្រទេសកម្ពុជានឹងអាចកាត់បន្ថយបានយ៉ាងច្រើននូវការ ចំណាយកាតព្វកិច្ចបញ្ញត្តិកម្ម។ នៅពេលយើងធ្វើពិធីផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទ ដ្ឋានគតិយុត្តជាផ្លូវការ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២កន្លងទៅនេះ យើងទទួលបាន ពិសោធន៍ពីប្រទេសអនុវត្ត RIA ក្នុងការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តដែលតម្រូវដោយរដ្ឋាភិបាល មួយពីវាគ្មិនមកពីប្រទេសអូស្ត្រាលី និងមួយទៀតមកពីប្រទេសវៀតណាម។ ប្រទេសអូស្ត្រាលីអនុវត្ត RIA បានល្អ ដោយមាននាយកដ្ឋានត្រួតពិនិត្យ និងមានធនធានគ្រប់គ្រាន់។ ឯប្រទេសវៀតណាមអនុវត្ត RIA មិនសូវបានល្អ ដោយគ្មានការត្រួតពិនិត្យបានត្រឹមត្រូវ និងខ្វះធនធានមនុស្សផង។

ដូច្នេះការអនុវត្ត RIA សម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាល ទាមទារការគាំទ្រពីថ្នាក់ដឹកនាំ និង ពីក្រសួងដែលព្រាងលិខិតបទដ្ឋានគតិយុត្ត និងជាអ្នករៀបចំការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នោះ ឲ្យអនុវត្តវិធីសាស្ត្រ RIA បានម៉ត់ចត់។

គម្រោង RIA កំពុងដំណើរការទៅតាមផែនការ ដោយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ និង ក្រសួងទាំង០៤ ដែលចូលរួមអនុវត្ត RIA រួមមានក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍។ ឆ្លៀតឱកាសនេះ ខ្ញុំសូមកោតសសើរយ៉ាងជ្រាលជ្រៅដល់ក្រុមការងារ RIA ទាំងអស់ដែលបានសម្រេចបានវឌ្ឍនភាពយ៉ាងច្រើន។

ខ្ញុំយល់ថា RIA នេះជាឧបករណ៍ល្អមួយ និងជាការប្រតិបត្តិទម្លាប់ល្អសម្រាប់ការរៀបចំតាក់តែងលិខិត បទដ្ឋានគតិយុត្ត ហើយនៅក្នុងរយៈពេលវែង RIA នេះនឹងត្រូវអនុវត្តនៅទូទាំងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

សូមឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ និស្សិត លោក លោកស្រី ចូលរួមផ្តល់មតិយោបល់ស្ថាបនាក្នុង សិក្ខាសាលានេះ ឲ្យទទួលបានផ្លែផ្កាល្អ។ ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលតែងតែណែនាំ ចង្អុលបង្ហាញ និងគាំទ្រដល់គម្រោង RIA នេះជានិច្ច។"

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ចាន់ តិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង វត្ថមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ឆារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត កក្កដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in